# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ០៤ អនក

## សេចក្ដីសម្រេច

## ស្ដីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំ រេ ច

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅរដ្ឋគូវែត ចាប់ពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩ រហូតដល់ពេលសម្ដេចតេជោនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាលគ្រប់ខេត្ត និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្ដីសម្រេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៩*

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២*
- *ឯកសារ-កាលប្បវត្តិ*